មជ្ឈមណ្ឌលឯកសារកម្ពុជា

**ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា**

**ការបង្រៀនអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»**

# វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ

**កម្មវិធីបង្រៀនរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា**

**សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា**

## *តើអ្វីជាកម្មវិធីបង្រៀន?*

*កម្មវិធីបង្រៀនគឺជាគម្រោងប្រធានបទ ដែលត្រូវបង្រៀននៅក្នុងវគ្គសិក្សា ដែលសាស្ត្រាចារ្យគ្រប់រូបសរសេរនិងចែកជូននិស្សិតនៅថ្ងៃចូលរៀនដំបូង ។ កម្មវិធីបង្រៀនពាំនាំមកជូននូវកម្មវត្ថុ និងសេចក្តីរំពឹងរបស់និស្សិត ។*

*ជាទូទៅ កម្មវិធីបង្រៀន រួមមានព័ត៌មានជាក់ស្តែងដូចខាងក្រោមស្តីពីវគ្គបង្រៀនដើម្បីនាំផ្លូវនិស្សិត និងធ្វើឲ្យការរៀនមានកម្រិតអតិបរមា ។*

- *ចំណងជើងនៃវគ្គសិក្សា និងពេលវេលាជួបប្រជុំ*
- *ឈ្មោះសាស្ត្រាចារ្យ និងព័ត៌មានសម្រាប់ទំនាក់ទំនង*
- *ការពិពណ៌នាអំពីវគ្គសិក្សា*
- *អត្ថបទតម្រូវឲ្យអាន និងសម្ភារៈដទៃទៀត*
- *កម្មវត្ថុរបស់វគ្គសិក្សា*
- *សេចក្តីរំពឹងទុក និងគោលការណ៍ចុះវត្តមាន*
- *ប្រធានបទរបស់វគ្គសិក្សា និងជំពូកដែលត្រូវរៀន*
- *កាលបរិច្ឆេទសាកល្បង*
- *កាលបរិច្ឆេទ ពាក់ព័ន្ធដទៃទៀត*
- *គោលការណ៍នៃការដាក់ចំណាត់ថ្នាក់*
- *វិន័យ និងការអនុវត្តនៅក្នុងថ្នាក់*

## ហេតុអ្វីបានជាកម្មវិធីបង្រៀនមានសារៈសំខាន់?

កម្មវិធីបង្រៀន ជាសម្ភារៈដ៏សំខាន់ក្នុងវគ្គសិក្សា នៅតាមសាកលវិទ្យាល័យសម្រាប់និស្សិត សាស្ត្រាចារ្យនិងសហគមន៍បញ្ញវន្ត ដោយសារតែការរៀនសូត្រ និងការវាយតម្លៃរបស់និស្សិតព្រមទាំងផ្តល់នូវក្របខ័ណ្ឌ ដើម្បីរំពឹងទុកជាមុនចំពោះអាទិភាពរបស់សាស្ត្រាចារ្យ និងយល់អំពីបញ្ហារបស់ប្រធានបទនីមួយៗ ។

កម្មវិធីបង្រៀន អនុញ្ញាតឲ្យសាស្ត្រាចារ្យឆ្លងកាត់ការគិតអំពីប្រធានបទក្នុងរបៀបដែលមិនគ្រាន់តែអាចយល់បានសម្រាប់និស្សិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់សហការីនិងសហគមន៍បញ្ញវន្តទៀតផង ដែលអាចពិនិត្យមើលទៅលើកម្មវិធីបង្រៀនរបស់សាស្ត្រាចារ្យ ក្នុងគោលបំណងដើម្បី កំណត់អំពីសម្ភារៈ និងវិសាលភាពរបស់វគ្គសិក្សា ។ ដេប៉ាតឺម៉ង់នៅតាមសាកលវិទ្យាល័យតែងតែតម្រូវឲ្យក្រុមសាស្ត្រាចារ្យសហការគ្នាដើម្បីធ្វើគម្រោងបង្រៀនក្នុងគោលបំណងបង្កើតវិសាលភាពដ៏ស្អិតរមួត និងគ្រប់ជ្រុងជ្រោយរបស់ប្រធានបទសម្រាប់បង្រៀនរបស់ដេប៉ាតឺម៉ង់នីមួយៗ ។ លើសពីនេះទៀត កម្មវិធីបង្រៀននេះអនុញ្ញាតឲ្យសាស្ត្រាចារ្យមានឱកាសក្នុងការប្រៀបធៀបចំពោះការយល់ឃើញរបស់ខ្លួនទៅលើប្រធានបទជាក់លាក់ណាមួយ ដោយអនុញ្ញាតឲ្យមានការអភិវឌ្ឍវិជ្ជាជីវៈ និងការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ។

សម្រាប់និស្សិតវិញ កម្មវិធីបង្រៀននេះអាចត្រូវបានចាត់ទុកថាជា កិច្ចសន្យាផ្ទាល់ខ្លួនរវាងនិស្សិតម្នាក់ៗនិងសាស្ត្រាចារ្យ ។ សាស្ត្រាចារ្យសន្យាថានឹងបំពេញមុខនាទីដ៏ជាក់លាក់និងគ្របដណ្តប់លើប្រធានបទជាក់លាក់នៅក្នុងវគ្គសិក្សា ដើម្បីជាផលប្រយោជន៍របស់និស្សិត ។ កម្មវិធីបង្រៀនក៏គូសបញ្ជាក់ពីការរំពឹងទុករបស់សាស្ត្រាចារ្យទៅលើនិស្សិតម្នាក់ ទាក់ទងទៅនឹងអ្វីដែលត្រូវបំពេញ និងនៅក្នុងបទដ្ឋានកម្រិតណាដែលនិស្សិតត្រូវធ្វើ ដើម្បីទទួលបាននូវការវាយតម្លៃដ៏ជោគជ័យពីសំណាក់សាស្ត្រាចារ្យ ។ ក្នុងន័យនេះ វាជាការសំខាន់ ដែលសាស្ត្រាចារ្យត្រូវតែច្បាស់លាស់សម្រាប់ការរំពឹងទុកនោះ ដោយសារតែថា ទាក់ទងទៅនឹងការបកស្រាយ ការរំពឹងទុករបស់សាស្ត្រាចារ្យ និស្សិតនឹងងាកទៅរកកម្មវិធីបង្រៀនមុនគេបង្អស់ ។ កម្មវិធីបង្រៀនដ៏ច្បាស់លាស់ និងរៀបចំយ៉ាងល្អនឹងជួយការពារសាស្ត្រាចារ្យពីអំណះអំណាងមានលក្ខណៈស្រពេចស្រពិល ហើយជារួម នឹងអនុញ្ញាតឲ្យសាស្ត្រាចារ្យចៀសវាងនូវការសន្ទនាដ៏គួរឲ្យធុញទ្រាន់អំពីវគ្គសិក្សានោះជាពិសេសភាពលម្អិតរបស់ផ្នែករដ្ឋបាល ។ ជាពិសេស កម្មវិធីបង្រៀននេះជាឧបករណ៍គ្រប់គ្រងពេលវេលា និងការការពារផ្នែករដ្ឋបាលសម្រាប់ក្រុមសាស្ត្រាចារ្យទៀតផង ។

## កម្មវិធីបង្រៀន

សាស្ត្រាចារ្យ ៖ ............................

ពេលវេលានៅការិយាល័យ ៖ ...........

កាលបរិច្ឆេទ និងទីតាំង ៖ ................

ទូរស័ព្ទ ៖ ...................................

អ៊ីម៉ែល ៖...................................

## *អត្ថបទតម្រូវឲ្យអាន*

- ឌី ខាំបូលី (២០០៧) *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩).* មជ្ឈមណ្ឌលឯកសារកម្ពុជា
- ប៊ូនស៍ អាដាម (២០០៦) *អំពើប្រល័យពូជសាសន៍ ៖ ការណែនាំគ្រប់ជ្រុងជ្រោយ*
- ប៉ែត វ៉ាន់ស្កាក់ (១៩៩៧) *"និយមន័យអំពើប្រល័យពូជសាសន៍៖ ការកែតម្រូវចំណុចខ្វះខាតក្នុងនិយមន័យអំពើប្រល័យពូជសាសន៍"* ព្រឹត្តិបត្រច្បាប់សាកលវិទ្យាល័យយ៉េល

## *អត្ថបទដកស្រង់*

- អៀ ម៉េងទ្រី (២០០៨) *ខ្សែសង្វាក់នៃអំពើឃោរឃៅ ៖ ប្រព័ន្ធសន្តិសុខនៅភូមិភាគនិរតីរបស់ខ្មែរក្រហម*
- អៀន ហារីស. (២០០៧). ព្រះពុទ្ធសាសនាក្រោមរបប ប៉ុល ពត
- អ៊ីសា ឧស្មាន (២០០៦) *ការបះបោររបស់ជនជាតិចាម ៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីមូលដ្ឋាន*

## *អត្ថបទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

- ដេវីត ឆេនល័រ (១៩៩៩) សំឡេងពីមន្ទីរស-២១ ៖ អំពើឃោរឃៅនិងប្រវត្តិសាស្ត្រនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត
- ចន ឆរឆីអារី. (២០០៦). *តុលាការខ្មែរក្រហម*

- ចន ឆរឆីអារី និង អាន ហេនឌុល (២០០៩) ការកាត់ទោស ៖ ដំណើការនៃការទទួលខុសត្រូវរបស់ខ្មែរក្រហម
- វ៉េនី ខជៀល, ប៉ាង ពីវីន, រ៉ា ឆៃរ៉ាន់ និង ស៊ឹម សុភ័ក្រ (២០០៤) ជីវិតក្នុងភាពនឹងថ្កល់ ៖ រូបថតនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា
- អៀ ម៉េងទ្រី (២០០៤) ខ្សែសង្វាក់នៃអំពើឃោរឃៅ ៖ ប្រព័ន្ធសន្តិសុខនៅភូមិភាគនិរតីរបស់ខ្មែរក្រហម
- អៀ ម៉េងទ្រី និង ស៊ឹម សូរិយា(២០០១) ជនរងគ្រោះ និងជនដៃដល់ ៖ សក្ខីកម្មរបស់កម្មាភិបាលក្មេងៗនៅមន្ទីរស-២១
- អៀន ហារីស (២០០៧) ព្រះពុទ្ធសាសនាក្រោមរបប ប៉ុល ពត
- ស្ទីវ ហេឌើ និង ប្រាយអិន ធីតម័រ(២០០៤) បេក្ខជនប្រាំពីរនាក់ដែលត្រូវកាត់ទោស ៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម
- ហ៊ុយ វណ្ណៈ (២០០៣) កងពលខ្មែរក្រហមលេខ៧០៣ ៖ ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង
- ស៊ូហ្សាណា លីនតុន (២០០៤) ការផ្សះផ្សានៅកម្ពុជា
- ហ៊ុយ វណ្ណៈ (២០១០) ប៊ូ ម៉េង៖ អ្នករស់រានមានជីវិតពីមន្ទីរស-២១របស់ខ្មែរក្រហម
- ប៉ាង ពីវីន និង វ៉េនី ខជៀល (២០០៧) ក្លាយជាផេះផង់៖ រឿងរ៉ាវប្រជាជនថ្មីរបស់កម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
- ព្រីនស៍ អានម៉ារី (២០០៨) ទម្លាយភាពស្ងប់ស្ងាត់
- អ៊ីសា ឧស្មាន (២០០២) អ៊ូគូបះ៖ យុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍សម្រាប់ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
- អ៊ីសា ឧស្មាន (២០០៦) ការបះបោររបស់ជនជាតិចាម ៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីមូលដ្ឋាន

**អត្ថបទគួរអាន ៖**

## *អត្ថបទជ្រើសរើសពីទស្សនាវដ្តី ស្វែងរកការពិត*

- អេង កុកថាយ. (២០០៦). ការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ឡើងវិញ

- សូ ហ្វារីណា. (២០១០) ប្រវត្តិសាស្ត្រផ្ទាល់មាត់ៈ រឿងរ៉ាវចេញពីសហគមន៍ចាមមូស្លីម

**អត្ថបទជ្រើសរើសពីព្រឹត្តិបត្រស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ ការសិក្សា និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដកស្រង់ពីព្រឹត្តិបត្រផ្សេងៗ**

- ចាយ៉ា រ៉ាមជី ណូហ្គាលេ (២០០០) រៀបចំយុត្តិធម៌អន្តរកាលតាមរបៀបប្រពៃណីៈ វិធីសាស្ត្រដំណើរការពហុនិយម
- ផាត់ កុសល (២០១១) កត្តាសេដ្ឋកិច្ចនាំទៅរកការប្រេះឆាររវាងចិននិងវៀតណាម ១៩៧២-៧៥ៈ ការវិភាគទៅលើបណ្ណសារដ្ឋានវៀតណាម
- អ៊ីវ៉ាន សុីម៉ូណូវីក(២០០៤) ឥរិយាបថនិងប្រភេទនៃប្រតិកម្មចំពោះបទឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល.
- ម៉ារៀម ដេអូឃីម៉ាន (២០០២) អំពើអាក្រក់មិនធម្មតា បទឧក្រិដ្ឋកម្មធម្មតាៈ ក្របខ័ណ្ឌយល់ដឹងអំពីយុត្តិធម៌អន្តរកាល.
- សារ៉ា វ៉ារសើ ហ្វ្រីម៉ាន (២០០៨) ការបង្រៀនប្រវត្តិសាស្ត្រ ក្រោយពីជម្លោះខាងអត្តសញ្ញាណៈ បទពិសោធប្រទេសរ៉្វាន់ដា.

**អត្ថបទពីសារព័ត៌មានផ្សេងៗ**

- នូសារ៉ា ថៃថារ៉ាត់ (២០០០) ប្រវត្តិជីវិតក្រោយពីសេចក្តីស្លាប់. បាងកកប៉ុស្តិ៍
- នូសារ៉ា ថៃថារ៉ាត់ (២០០៦) ការបង្កើតមនោគមវិជ្ជារបស់ខ្មែរក្រហម. បាងកកប៉ុស្តិ៍
- សិដ្ឋ ម៉ៃដិន (១៩៩៩) រឿងរ៉ាវរបស់ស្ត្រីកម្ពុជាម្នាក់ ៈ ធ្វើឲ្យមានកំហុសពីបទប្រល័យពូជសាសន៍. ញ៉ូយ៉កថែមស៍
- សិដ្ឋ ម៉ៃដិន (១៩៩៩). រូបថតរបស់ខ្មែរក្រហមៈ មិនហ៊ានញញឹម. ញ៉ូយ៉កថែមស៍
- ឆាំង យុ (២០០០) ក្រោមព្រះនេត្រព្រះពុទ្ធ រស្មីកម្ពុជា

***គេហទំព័រគួរមើល***

http://www.dccam.org/
http://www.cambodiatribunal.org/
http://www.cambodiasri.org/
http://www.eccc.gov.kh/
http://www.yale.edu/gsp/
http://www1.umn.edu/humanrts/instree/x1cppcg.htm
http://www1.umn.edu/humanrts/instree/b1udhr.htm
http://www.yale.edu/lawweb/avalon/imt/proc/imtconst.htm

## ការពិពណ៌នាអំពីវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងដើម្បីណែនាំនិស្សិតអំពីរយៈកាលប្រកបដោយសោកនាដកម្មបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា និងជំរុញឲ្យនិស្សិតពិនិត្យមើលអំពើប្រល័យពូជសាសន៍ និងទម្រង់ផ្សេងទៀតនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងពិភពលោកសម័យទំនើបនេះ ។ វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់ជូននូវមាគ៌ាមួយសម្រាប់និស្សិតដើម្បីឆ្លុះបញ្ចាំង និងវាយតម្លៃទៅលើអំពើប្រល័យពូជសាសន៍នៅកម្ពុជាយ៉ាងហ្មត់ចត់ និងវិធីសាស្ត្រ ដែលប្រទេសកម្ពុជាក្រោយជម្លោះ បានដោះស្រាយបញ្ហាយុត្តិធម៌ ការផ្សះផ្សា ការចូលរួមរបស់ប្រជាពលរដ្ឋ ភាពស្មោះត្រង់ និងភាពចុះសម្រុងគ្នា ។ តាមរយៈការសិក្សាអំពីអតីតកាល ដើម្បីយល់ពីបច្ចុប្បន្នកាល និស្សិតនឹងយល់ឃើញថា ខណៈដែលមនុស្សជាតិទាំងអស់មានសក្តានុពល ដើម្បីក្លាយទៅជាផ្នែកមួយនៃដំណើរការប្រកបដោយភាពបំផ្លិចបំផ្លាញ អ្នកទាំងនោះ ក៏មានអំណាចដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរសង្គមប្រកបដោយភាពវិជ្ជមាន និងការផ្លាស់ប្តូរគន្លងប្រវត្តិសាស្ត្រជារួមដែរ ។

វគ្គបណ្តុះបណ្តាលនេះ នឹងជំរុញនិស្សិតឲ្យលើកតម្លៃកាន់តែជ្រាលជ្រៅថែមទៀត ស្តីពីភាពស្មុគស្មាញនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងសង្គមកម្ពុជានាពេលសព្វថ្ងៃនេះ ។ វគ្គបណ្តុះបណ្តាលនេះក៏នឹងប្រើប្រាស់ប្រភពឯកសារដើម ឯកសារសៀវភៅ កំណត់ហេតុប្រជុំ ខ្សែភាពយន្ត និង ប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ។ នៅចុងវគ្គនេះ តាមរយៈការបំពេញតាមតម្រូវការយ៉ាងសកម្ម ជាពិសេសការបញ្ចប់ការអាន និងការឆ្លើយតបចំពោះកិច្ចការ ការពិភាក្សាក្នុងថ្នាក់ ការធ្វើបទបង្ហាញ និងការស្រាវជ្រាវ និស្សិតនឹងអភិវឌ្ឍការត្រិះរិះពិចារណា ការអាន ការសរសេរ និងជំនាញក្នុងការធ្វើសុន្ទរកថាសាធារណៈទៀតផង ។

## គោលបំណងរបស់វគ្គបណ្តុះបណ្តាល

១. ដើម្បីធ្វើឲ្យយល់អំពីប្រវត្តិសាស្ត្រនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យ តាមរយៈការវិភាគ និងវាយតម្លៃទៅលើមនោគមវិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ប្រៀបធៀបចក្ខុវិស័យ និងការអង្កេតខុសៗគ្នាទៅលើរបបខ្មែរក្រហម ។

២. ដើម្បីវាយតម្លៃទៅលើការយល់ដឹងរបស់អ្នករស់រានមានជីវិត និងជំរុញឲ្យមានការពិភាក្សាជាមួយមនុស្សវ័យចំណាស់ (ឧទាហរណ៍ បទសម្ភាស ប្រវត្តិគ្រួសារ) ។ល ។

៣. ដើម្បីត្រិះរិះពិចារណាអំពីមូលហេតុដែលថាហេតុនៃអំពើហិង្សាទ្រង់ទ្រាយធំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងផលប៉ះពាល់ និងផលវិបាក ។

៤. ដើម្បីពិនិត្យមើលអំពីទម្រង់ផ្សេងៗ នៃអំពើឃោរឃៅរបស់រដ្ឋ និងឥទ្ធិពលទៅលើសង្គមផ្សេងៗគ្នា ដើម្បីរកឲ្យឃើញថាតើហេតុអ្វីបានជាអំពើហិង្សារបស់បដិវត្តន៍កម្ពុជាប្រជាធិប-តេយ្យ អាចនាំទៅរកអំពើប្រល័យពូជសាសន៍ ។
៥. ដើម្បីវាយតម្លៃផលប៉ះពាល់មួយចំនួនរបស់របបខ្មែរក្រហមទៅលើ ប្រទេសកម្ពុជានាពេលសព្វថ្ងៃ ។
៦. ដើម្បីជំរុញឲ្យមានសេចក្ដីករុណា និងការយោគយល់ ព្រមទាំងពិចារណាទៅលើនិយមន័យ និងភាពចាំបាច់សម្រាប់ការផ្សះផ្សា នៅក្នុងសង្គមកម្ពុជា ។
៧. ដើម្បីពិនិត្យមើលទៅលើសំណួរ ដែលថាត្រូវធ្វើអ្វីខ្លះក្នុងការទប់ស្កាត់អំពើឃោរឃៅរបស់មនុស្ស អំពើហិង្សាទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ ។

## លទ្ធផលនៃវគ្គសិក្សា

និស្សិតនឹងអាចមានលទ្ធភាពក្នុងការ

១. យល់ច្បាស់បញ្ហាជុំវិញនិយមន័យនៃពាក្យ «អំពើអាក្រក់» និងពិភាក្សាពីភាពខុសប្លែកគ្នាលើទស្សនៈវិស័យស្ដីពីអំពើអាក្រក់សម្រាប់ជនរងគ្រោះ និងជនដៃដល់ ។
២. យល់ច្បាស់អំពីនិយមន័យអំពើប្រល័យពូជសាសន៍ ការផ្សះផ្សា និងអំពើហិង្សាទ្រង់ទ្រាយធំ និងពិភាក្សាអំពីការលំបាកជុំវិញនិយមន័យនីមួយៗ ។
៣. ពិភាក្សាអំពីអន្តរសកម្មភាពនៃកត្តាដែលដើរតួនាទីដ៏មានសក្ដានុពល ក្នុងការប្រព្រឹត្តអំពើអាក្រក់ និងភាពឃោរឃៅរបស់មនុស្ស តាមរយៈបុគ្គល និងសមូហភាព (ឧទាហរណ៍ អំពើទារុណកម្ម និងប្រល័យពូជសាសន៍ជាដើម) ។
៤. យល់ច្បាស់អំពីទ្រឹស្ដីនៃហេតុផល និងការបង្ហាញ ឬពិភាក្សាថាតើទ្រឹស្ដីអាចអនុវត្តទៅលើការកើតឡើងនូវអំពើហិង្សាទ្រង់ទ្រាយធំ ឬអំពើប្រល័យពូជសាសន៍នៅប្រទេសអាល្លឺម៉ង់ អ៊ីរ៉ាក់ កម្ពុជា យូហ្គោស្លាវី និងរ៉្វាន់ដា ។
៥. យល់ច្បាស់អំពីទស្សនៈ ដែលពិនិត្យមើលទៅលើការទប់ស្កាត់ភាពឃោរឃៅរបស់មនុស្ស អំពើហិង្សាទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ ឬការធ្វើអន្តរាគមន៍ក្នុងអំឡុងពេលមានអំពើហិង្សាទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ ។
៦. សរសេរអត្ថបទស្រាវជ្រាវ ដែលវិភាគករណីអំពើហិង្សាទ្រង់ទ្រាយធំ (អំពើប្រល័យពូជសាសន៍) ដែលមិនទាន់ពិភាក្សានៅក្នុងថ្នាក់ ឬអត្ថបទនេះ ។

### របៀបដាក់ចំណាត់ថ្នាក់

| | |
|---|---|
| ៩០-១០០ ពិន្ទុ | ក= ល្អណាស់ |
| ៨០-៨៩ ពិន្ទុ | ខ= លើសមធ្យម |
| ៧០-៧៩ ពិន្ទុ | គ= មធ្យម |
| ៦០-៦៩ ពិន្ទុ | ឃ= ក្រោមមធ្យម |
| តិចជាង ៦០ ពិន្ទុ | ង= ធ្លាក់ |

### ភាគរយនៃចំណាត់ថ្នាក់

| | |
|---|---|
| វត្តមាន និងការចូលរួម | ១០ ភាគរយ |
| កិច្ចការប្រកបដោយភាពច្នៃប្រឌិត : ការសរសេរកំណត់ហេតុ ការធ្វើសម្ភាសន៍ ឬបង្កើតកម្មវិធីសិល្បៈនិងកំណាព្យ | ២០ ភាគរយ |
| ការសិក្សាអំពីប្រធានបទៈការស្រាវជ្រាវឯករាជ្យ និងបទបង្ហាញ | ២៥ ភាគរយ |
| អត្ថបទឆ្លើយតប (៤) | ២០ ភាគរយ |
| ប្រឡងបញ្ចប់ | ២៥ ភាគរយ |

**គោលការណ៍វត្តមាន :**

វត្តមានក្នុងពេលបង្រៀននិងផ្នែកការពិភាក្សាជាសមាសភាពដ៏សំខាន់នៅក្នុងដំណើការរៀនសូត្រសម្រាប់វគ្គបណ្តុះបណ្តាលនេះ ។ មានការរំពឹងទុកថានិស្សិតនឹងចូលរួមគ្រប់ការបង្រៀននិងការពិភាក្សា ។ ប្រសិនបើនិស្សិតមិនអាចចូលរួមក្នុងថ្នាក់ដោយសារប្រការណាមួយ និស្សិតត្រូវជូនដំណឹងទៅសាស្ត្រាចារ្យនៅក្នុងថ្នាក់ជាមុនតាមរយៈអ៊ីម៉េល ទាក់ទងនឹងការអវត្តមាន និងហេតុផលនៃអវត្តមាន នោះផង ។ អវត្តមានដោយគ្មានការពន្យល់ ឬច្រើនដង នឹងប៉ះពាល់ដល់ចំណាត់ថ្នាក់របស់និស្សិត ។

**សេចក្តីបញ្ជាក់ពីគោលការណ៍**

ការលួចចម្លង(មានន័យថាការចម្លងអ្វីដែលអ្នកដទៃបានសរសេររួចហើយដោយធ្វើដូចជាអ្នកបានសរសេរដោយខ្លួនឯង) គឺមិនអាចទទួលយកបានឡើយ ។ ការលួចចម្លងនឹងទទួលលទ្ធផលសូន្យសម្រាប់កិច្ចការនោះ ។ ការលួចចម្លងត្រូវបានកំណត់ថាជាការប្រើសម្ភារៈឬព័ត៌មាន ដែលមិនត្រូវបានដកស្រង់ដោយផ្ទាល់ ។ ខណៈដែលនិស្សិតម្នាក់ៗត្រូវបានលើកទឹកចិត្តឲ្យដកស្រង់ព័ត៌មាន ដើម្បីគាំទ្រដល់ចំណុច

ទាំងឡាយនៅក្នុងអត្ថបទរបស់ខ្លួន អត្ថបទនោះមិនត្រូវពឹងផ្អែកខ្លាំងទៅលើស្នាដៃឬសម្ភារៈរបស់អ្នកដទៃ ថាតើស្នាដៃឬសម្ភារៈនោះត្រូវបានបោះពុម្ពផ្សាយឬទេ ។

**គម្រោងរបស់វគ្គបណ្តុះបណ្តាល**

| លេខរៀង | ប្រធានបទ | កិច្ចការ |
| --- | --- | --- |
| ១. | ណែនាំទៅកាន់និស្សិតអំពីថាតើអ្វីជា«អំពើអាក្រក់»? <br>ជនដៃដល់និងជនរងគ្រោះ តើអ្វីជាអំពើប្រល័យពូជសាសន៍? <br><br>**វត្ថុបំណង** <br>១. ទទួលបានចំណេះដឹងលម្អិតទៅលើមូលដ្ឋានប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ <br>២. ស្វែងរក កំណត់និយមន័យ និងប្រើពាក្យសំខាន់ៗ និងឈ្មោះ ។ <br>៣. យល់អំពីខ្លឹមសារសីលធម៌ជារួមក្នុងការសិក្សាអំពើប្រល័យពូជសាសន៍ ។ | សូមអាន ៖ <br>*ឌី ខាំបូលី(២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩)* <br>ជំពូកទី១ ៖ សេចក្តីសង្ខេប <br>ជំពូកទី២ ៖ តើខ្មែរក្រហមជាអ្នកណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? <br><br>សេចក្តីដកស្រង់ចេញពី ចូនស៍ អាដាម *អំពើប្រល័យពូជសាសន៍៖ ការណែនាំគ្រប់ជ្រុងជ្រោយ* ។ |
| ២. | អំពើប្រល័យពូជសាសន៍ ឬការសម្លាប់រង្គាល ៖ គោលគំនិតសំខាន់កំណត់និយមន័យអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសិទ្ធិមនុស្ស ។ <br><br>អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ។ <br><br>ពិភាក្សាកិច្ចការសម្រាប់អានតាមរយៈការអានរួមគ្នា ។ | *ឌី ខាំបូលី(២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)* <br><br>ច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬកតិកាសញ្ញាទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ <br><br>ប៊ែតវ៉ាន់ស្កាក់ *«និយមន័យនៃអំពើប្រល័យពូជសាសន៍ ៖ កែតម្រូវចំណុចខុះខាតក្នុង* |

| | | |
|---|---|---|
| | **វត្ថុបំណង**<br>១. ពិពណ៌នាពីអំពើប្រល័យពូជសាសន៍ដូចបានកំណត់ក្នុងនិយមន័យនៃច្បាប់អន្តរជាតិ ។<br>២. រៀនសមាសធាតុផ្សេងៗនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។<br>៣. យល់អំពីគម្លាតគ្នារវាងនិយមន័យអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ | *និយមន័យអំពើប្រល័យពូជសាសន៍» ព្រឹត្តិបត្រច្បាប់ សាកលវិទ្យាល័យយ៉េល (១៩៩៧)* ។<br><br>*អេង កុកថាយ ការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ឡើងវិញ* ។<br><br>តម្រូវឲ្យមានអត្ថបទឆ្លើយតប ។ |
| ៣. | ការត្រួតពិនិត្យជាទូទៅៈ ការបោសសម្អាតជនជាតិ ការសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍នៅសម័យទំនើប ។<br><br>**វត្ថុបំណង**<br>១. ពិនិត្យមើលទៅលើការបោសសម្អាតជាតិសាសន៍ ការសម្លាប់ក្នុងទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ក្នុងសម័យទំនើប ។<br>២. ពិពណ៌នាអំពីថាតើខ្មែរក្រហមបានគ្រប់គ្រងប្រទេសយ៉ាងដូចម្តេច ។<br>៣. ស្វែងរកទស្សនៈវិស័យសំខាន់ស្តីពីការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ។ | សូមអាន ៖<br>ឌី ខាំបូលី(២០០៧) *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)*<br>ជំពូកទី៣ ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម<br>ជំពូកទី៤ ៖ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ<br><br>សូមអាន ៖<br>អត្ថបទរបស់ ចូនស៍ អាដាម (២០០៦) *អំពើប្រល័យពូជសាសន៍ ៖ ការណែនាំគ្រប់ជ្រុងជ្រោយ* ។<br><br>តម្រូវឲ្យមានអត្ថបទឆ្លើយតប ។ |

| | | |
|---|---|---|
| ៤. | ប្រវត្តិសាស្ត្រកម្ពុជា និងការងើបឡើងនៃរបបខ្មែរក្រហម ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br><br>**វត្ថុបំណង**<br>១. ពិពណ៌នាអំពីការបែងចែករដ្ឋបាលផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ ។<br>២. ប្រៀបធៀបភាពខុសគ្នារវាងភូមិភាគ និងមូលហេតុនៃការបែងចែក ។<br>៣. ពិពណ៌នាអំពីផែនការបួនឆ្នាំ ។<br>៤. ស្វែងរក កំណត់និយមន័យ និងប្រើពាក្យគន្លឹះ និងឈ្មោះ ។ | សូមអាន ៖<br>ឌី ខាំបូលី(២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)<br><br>ជំពូកទី៥ ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម<br>ជំពូកទី៦ ៖ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ<br><br>សេចក្តីដកស្រង់ពី អៀន ហារីស ពុទ្ធសាសនាក្រោមរបបប៉ុល ពត។<br><br>តម្រូវឲ្យមានអត្ថបទឆ្លើយតប ។ |
| ៥. | មនោគមវិជ្ជា និងគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩ ផ្នែកទី១ ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br><br>ការបញ្ចាំងខ្សែភាពយន្តៈ នៅគៀនជញ្ជាំងមន្ទីរស-២១ ។ | សូមអាន ៖<br>ឌី ខាំបូលី(២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)<br>ជំពូកទី៧ ៖ ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>ជំពូកទី៨ ៖ ប្រព័ន្ធសន្តិសុខ<br>ជំពូកទី៩ ៖ មន្ទីរស-២១(គុកទួលស្លែង)<br>ជំពូកទី១០ ៖ ទំនាក់ទំនងការបរទេស<br><br>នូសាក៊ា ថៃថាភ៊ត់ |

| | | |
|---|---|---|
| | **វត្ថុបំណងនៃការរៀន**<br>១. វិភាគថាតើជីវិតមានសភាពយ៉ាងដូចម្ដេចខ្លះនៅក្រោមរបបខ្មែរក្រហម ។<br>២. ស្វែងរកទស្សនៈវិស័យសំខាន់ស្ដីពីប្រព័ន្ធសន្ដិសុខខ្មែរក្រហម ។<br>៣. ពន្យល់ព័ត៌មានសំខាន់ៗអំពីគុកទួលស្លែង ។<br>៤. ពន្យល់អំពីសារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ ។<br>៥. ស្វែងរក កំណត់និយមន័យ និងប្រើពាក្យគន្លឹះនិងឈ្មោះ ។ | ប្រវត្តិសាស្ត្រជីវិតក្រោយសេចក្ដីស្លាប់ ។<br><br>តម្រូវឲ្យមានអត្ថបទឆ្លើយតប ។ |
| ៦. | មនោគមវិជ្ជា និងគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩ ផ្នែកទី២ ។<br><br>ផលប៉ះពាល់របស់របបខ្មែរក្រហមទៅលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។<br><br>អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br><br>ភ្ញៀវ ៖ ក្រុមអ្នករស់រានមានជីវិត ។<br><br>**វត្ថុបំណង** | សូមអាន ៖<br>ឌី ខាំបូលី(២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)<br>ជំពូកទី១១ ៖ ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ<br><br>សេចក្ដីដកស្រង់ពី អ៊ីសា ខស្ម៉ុន អ៊ីតូបះ ៖ យុត្តិធម៌នៃអំពើប្រល័យពូជសាសន៍សម្រាប់ជនជាតិចាមមូស្លីមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។<br><br>អត្ថបទស្ដីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។<br><br>នូសារ៉ា ថៃថាវ៉ាត់ |

| | | |
|---|---|---|
| | ១. ពន្យល់អំពីទំហំនៃផលប៉ះពាល់របស់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមទៅលើជីវិត និងស្មារតីជនរង-គ្រោះ ។<br>២. ទទួលស្គាល់សេចក្ដីក្លាហាននិងភាពរឹងមាំរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើពាក្យគន្លឹះនិងឈ្មោះ ។ | សមមិត្ត នួន ជា ៖ *ការកសាងអ្នកដើរតាមមនោគមវិជ្ជាខ្មែរក្រហម។* |
| ៧. | អំពើប្រល័យពូជសាសន៍តាមការប្រៀបធៀបហេតុអ្វីនិងហេតុដូចម្ដេចបានជាយើងសិក្សាពីអំពើប្រល័យពូជសាសន៍តាមការប្រៀបធៀប?<br><br>យុទ្ធនាការរបស់អ៊ីរ៉ាក់ប្រឆាំងជនជាតិឃឺដ<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br>**វត្ថុបំណង**<br>១. ប្រៀបធៀបការសម្លាប់ទ្រង់ទ្រាយធំ ។<br>២. ប្រើការសរសេរប្រកបដោយការបង្កើតថ្មី បទសម្ភាសឬកំណាព្យដើម្បីយល់កាន់តែស៊ីជម្រៅពីការសម្លាប់ទ្រង់ទ្រាយធំឬអំពើប្រល័យពូជសាសន៍ ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើ | សូមអាន ៖<br>អត្ថបទ នឹងត្រូវប្រកាសឲ្យដឹង ។<br><br>កិច្ចការនៃស្នាដៃច្នៃប្រឌិត ។ |

| | | |
|---|---|---|
| | ពាក្យគន្លឹះនិងឈ្មោះ ។ | |
| ៨. | តើនរណាជាជនដៃដល់? តើមនុស្សធម្មតាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលយ៉ាងដូចម្តេច?<br><br>ការសម្លាប់របស់ពួកណាហ្ស៊ី ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br>**វត្ថុបំណង**<br>១. ប្រៀបធៀបការសម្លាប់ទ្រង់ទ្រាយធំ ។<br>២. ស្វែងយល់ពីការពិពណ៌នារបស់អ្នកនៅក្បែរជនរងគ្រោះ និងជនដៃដល់ ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើពាក្យគន្លឹះនិងឈ្មោះ ។ | សូមអាន ៖<br>អត្ថបទ នឹងត្រូវប្រកាសឲ្យដឹង ។<br><br>សេចក្តីដកស្រង់ពី ដានីញ៉ែល ហ្គោលហាហ្គេន ពេជ្ឈឃាតប្រកបដោយសុឆន្ទៈរបស់ហ៊ីត្លែរ ៖ ជនជាតិអាល្លឺម៉ង់និងការសម្លាប់រង្គាល ។<br><br>សេចក្តីដកស្រង់ពី ឡូរ៉េល ហ្វេតឈើ ចេញពីភាពមិនខុសប្លែកគ្នាទៅកាន់ភាពរួបរួមគ្នា ៖ អ្នកនៅក្បែរនិងយុត្តិធម៌ខ្រិដ្ឋកម្មអន្តរជាតិ។ |
| ៩. | តើសារជាតិរបស់អំពើប្រល័យពូជសាសន៍មានអ្វីខ្លះ? តើនរណាជាជនរងគ្រោះ?<br><br>អំពើប្រល័យពូជសាសន៍នៅរ្វ៉ាន់ដា ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈអានរួមគ្នា ។<br><br>ការធ្វើបទបង្ហាញ ។<br><br>**វត្ថុបំណង** | សូមអាន ៖<br>អត្ថបទ នឹងត្រូវប្រកាសឲ្យដឹង ។<br><br>សេចក្តីដកស្រង់ពី អាលីសុន ដេសហ្វ័រហ្គេស កុំទុកឲ្យនរណាម្នាក់នៅរស់និយាយរឿងនោះឲ្យសោះ ។<br><br>សេចក្តីដកស្រង់ពីហ្វីលីព ហ្គូរ៉េវីត យើងសូមជូនដំណឹងដល់អ្នកថា យើងនឹងត្រូវសម្លាប់ជាមួយនឹងក្រុមគ្រួសារនៅថ្ងៃស្អែក។ |

| | | |
|---|---|---|
| | ១. ប្រៀបធៀបការសម្លាប់ទ្រង់ទ្រាយធំ ។<br>២. បង្ហាញពីការរៀនតាមរយៈការធ្វើបទបង្ហាញ ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើពាក្យគន្លឹះ និងឈ្មោះ ។ | តម្រូវឲ្យមានបទបង្ហាញពីការសិក្សាប្រៀបធៀប ។ |
| ១០. | តើយន្តកម្មទទួលខុសត្រូវបានបង្កើតឡើងដើម្បីដោះស្រាយអំពើហិង្សាដូចម្តេចខ្លះ? តើយន្តកម្មនោះជោគជ័យដែរឬទេ?<br><br>អំពើហិង្សាទ្រង់ទ្រាយធំនៅអតីតប្រទេសយូហ្គោស្លាវី ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br><br>ការធ្វើបទបង្ហាញ ។<br>**វត្ថុបំណង**<br>១. ប្រៀបធៀបការសម្លាប់ទ្រង់ទ្រាយធំ ។<br>២. បង្ហាញពីការរៀនតាមរយៈការធ្វើបទបង្ហាញ ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើពាក្យគន្លឹះ និងឈ្មោះ ។ | សូមអាន ៖<br>អត្ថបទ នឹងត្រូវប្រកាសឲ្យដឹង ។<br><br>សេចក្តីដកស្រង់ពីអត្ថបទរបស់ ហាវើ វើនស្តេន ឡូវ៉េល ហ្វេតឈើ ។<br><br>តម្រូវឲ្យមានបទបង្ហាញពីការសិក្សាប្រៀបធៀប ។ |
| ១១. | ការទប់ស្កាត់ និងការទទួលខុសត្រូវចំពោះអំពើហិង្សាទ្រង់ទ្រាយធំ | សូមអាន ៖<br>អត្ថបទ នឹងត្រូវប្រកាសឲ្យដឹង ។ |

| | | |
|---|---|---|
| | ការធ្វើអន្តរាគមន៍ ការទទួលខុសត្រូវចំពោះអំពើហិង្សាទ្រង់ទ្រាយធំ ។<br><br>ពិភាក្សាអំពីកិច្ចការអានតាមរយៈការអានរួមគ្នា ។<br>**វត្ថុបំណង**<br>១. ប្រៀបធៀបការសម្លាប់ទ្រង់ទ្រាយធំ ។<br>២. បង្ហាញពីការរៀនតាមរយៈការធ្វើបទបង្ហាញ ។<br>៣. ស្វែងរក កំណត់និយមន័យនិងប្រើពាក្យគន្លឹះ និងឈ្មោះ ។ | សេចក្ដីដកស្រង់ពីអត្ថបទរបស់ ហ្គារ៉េត អេវ៉ាន ស្ដីពីការទទួលខុសត្រូវចំពោះការការពារ ។<br><br>សេចក្ដីដកស្រង់ពី *ដូច្នេះយើងនឹងមិនបំភ្លេចបានទេ ៖ ការស្ទាបស្ទង់មតិផ្អែកលើប្រជា-ពលរដ្ឋស្ដីពីឥរិយាបថទាក់ទងនឹងការកសាងសង្គមនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ។<br><br>តម្រូវឲ្យមានអត្ថបទស្រាវជ្រាវឯករាជ្យ ។ |
| ១២. | ការបញ្ចប់ ឬពិភាក្សាអំពីវគ្គចុងក្រោយ អ្វីដែលយើងបានរៀន ។<br><br>ប្រឡងបញ្ចប់ ។<br><br>ការវាយតម្លៃទៅលើវគ្គបណ្ដុះបណ្ដាល ។<br><br>**វត្ថុបំណង**<br>១. សង្ខេបខ្លឹមសារមេរៀន ។<br>២. ពន្យល់ឲ្យយល់អំពីទស្សនៈសំខាន់ ។<br>៣. ពន្យល់ឲ្យយល់អំពីទស្សនៈប្រវត្តិសាស្ត្រ (ភាពយោគយល់ខាងប្រវត្តិសាស្ត្រ) ។ | |

**កិច្ចការសម្រាប់វគ្គសិក្សា ៖**

១) **អំណាន** ៖ សូមអានឯកសារ និងអត្ថបទដែលបានផ្តល់ឲ្យ និងបញ្ជាក់នៅក្នុងគម្រោងនៃវគ្គសិក្សា ដោយយកចិត្តទុកដាក់ដើម្បីត្រៀមខ្លួនពិភាក្សានៅក្នុងថ្នាក់រៀន ។

២) **អត្ថបទឆ្លើយតបចំនួន (៤)** គួររួមបញ្ចូលក្នុងសេចក្តីសង្ខេបនៃការបង្រៀន និងកិច្ចការអាន ។ អត្ថបទ នេះគួរតែមានពីពីរទំព័រទៅពីរទំព័រកន្លះ ។

៣) **ករណីសិក្សា** ៖

**ក) ការស្រាវជ្រាវឯករាជ្យ** ៖ ជ្រើសរើសប្រទេសមួយ ដែលធ្លាប់ជួបប្រទះអំពើប្រល័យពូជសាសន៍ ឬការសម្លាប់ក្នុងទ្រង់ទ្រាយធំ ។ សូមសរសេរសំណេរមួយដែលមានពី៥-៧ទំព័រ ដោយផ្តល់សេចក្តីលម្អិតអំពីប្រវត្តិសាស្ត្រ និងបទពិសោធនៃហេតុការណ៍នោះ ។

**ខ) បទបង្ហាញអំពីអំពើប្រល័យពូជសាសន៍បែបប្រៀបធៀប** ៖ សូមប្រើជំនាញធ្វើបទបង្ហាញផ្ទាល់មាត់ដើម្បីបង្ហាញជូននូវប្រធានបទនៃការសិក្សារយៈពេលពី៥-៧នាទី ។ សូមនិយាយឲ្យច្បាស់ ហើយប្រើរូបភាពអមមកជាមួយ ។

៤) **ការងារប្រកបដោយភាពច្នៃប្រឌិត** (សូមជ្រើសយកជម្រើសមួយក្នុងចំណោមជម្រើសទាំងបីខាងក្រោម) ៖

**ក) សំណេរបែបកំណត់ហេតុ ឬសំណេរបែបវិភាគ និងឆ្លុះបញ្ចាំង** ៖ សូមអានកំណត់ហេតុជីវិតដែលសរសេរដោយអ្នករស់រានមានជីវិតម្នាក់ ។ សូមសរសេរសំណេរបែបឆ្លុះបញ្ចាំង ដែលមានពី ២-៣ទំព័រ ដែលពិនិត្យមើលអំពីថាតើសៀវភៅនេះជួយអ្នកឲ្យយល់សារជាតិ និងតថភាពនៃបទពិសោធអំពើប្រល័យពូជសាសន៍ ។

**ខ) បទសម្ភាសៈ** បទសម្ភាសជាមួយអ្នករស់រានមានជីវិត របស់របបខ្មែរក្រហម (ឧទាហរណ៍ សាច់ញាតិ អ្នកជិតខាង មិត្តភក្តិឬគ្រូបង្រៀន) ហើយសរសេរអត្ថបទពី២-៣ទំព័រអំពីបទពិសោធរបស់អ្នក ។

**គ) សិល្បៈនិងកំណាព្យ** ៖ សូមសរសេរកំណាព្យអំពីសន្តិភាព និងការផ្សះផ្សា ។ សូមបង្កើតស្នាដៃសិល្បៈ ដូចជារូបថត គំនូរ ការផាត់ពណ៌ និងរូបចម្លាក់ឬទម្រង់ផ្សេងទៀតដែលជួយបកស្រាយគំនិតទាំងឡាយទាក់ទងនឹងកំណាព្យ ។

*៥) **ការប្រឡងបញ្ចប់** ៖ ការប្រឡងត្រូវបានរៀបចំឡើងដើម្បីសាកល្បងការយល់ដឹងពាក្យសំខាន់ៗ ទ្រឹស្តី គំនិត និងហេតុការណ៍ប្រវត្តិសាស្ត្រ ទាក់ទិននឹងអំពើសាហាវយង់ឃ្នងរបស់មនុស្ស អំពើហិង្សាទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ ដូចដែលបានបង្ហាញនៅក្នុងអត្ថបទ អំណាន មេរៀន ខ្សែវីដេអូនិងការពិភាក្សា ។*

*៦) **វត្តមាន, ការចូលរួម, និងការពិភាក្សា** ៖ ការចូលរួមសកម្មភាពនៅក្នុងថ្នាក់រៀន គឺពិតជាមានសារៈសំខាន់ៗ ការផ្តល់ពិន្ទុសម្រាប់ការចូលរួមសកម្មភាពនៅក្នុងថ្នាក់រៀន គឺផ្អែកទៅលើវត្តមានទៀងទាត់ និងការចូលរួមក្នុងបទពិភាក្សានិងវិភាគវែកញែកដែលធ្វើឡើងជារៀងរាល់ថ្ងៃ ។*

***កម្មវិធីបង្រៀន*** *ត្រូវបានសរសេរដោយ បណ្ឌិត ជា ផល្លា និងលោក គ្រីស្តូហ្វើ ឌៀរីង សហអ្នកនិពន្ធសៀវភៅណែនាំសម្រាប់គ្រូបង្រៀន សម្រាប់ការបង្រៀន«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានបោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំយុវជន និងកីឡា នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ២០០៩ ។*

***បណ្ឌិត ជា ផល្លា*** *ជាអ្នកឯកទេសនៅឯមជ្ឈមណ្ឌលព័ត៌មាននៅសាលារដ្ឋទីក្រុងឡូវើល នៃរដ្ឋម៉ាសាជូសេ៊ត ។ អ្នកស្រីទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកអប់រំ លើមុខជំនាញភាពជាអ្នកដឹកនាំសាលាមកពីសកលវិទ្យាល័យម៉ាសាជូសេ៊ត ។ អ្នកស្រីមានបទពិសោធជាច្រើនផ្នែកអភិវឌ្ឍកម្មវិធីសិក្សាវគ្គបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តកម្មវិធីសិក្សា ។*

***គ្រីស្តូហ្វើ ឌៀរីង*** *កំពុងតែរៀនបន្តយក* JD *ខាងច្បាប់អន្តរជាតិនៅសកលវិទ្យាល័យច្បាប់នៃទីក្រុងសេអាថល សហរដ្ឋអាមេរិក ។ លោកមានបទពិសោធផ្នែកការអប់រំយុវជន យុត្តិសាស្ត្រ ស៊ីវិល និងយោធាព្រមទាំងអភិវឌ្ឍកម្មវិធីសិក្សា ។*

***ពិនិត្យឡើងវិញដោយ***

**ដេវីត ឆេនល័រ** គឺជាសាស្ត្រាចារ្យចូលនិវត្តន៍ផ្នែកប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យម៉ូណាស (Monash University) ប្រទេសអូស្ត្រាលី ។ សាស្ត្រាចារ្យ ដេវីត ឆេនល័រ គឺជាប្រវត្តិវិទូដ៏ល្បីល្បាញម្នាក់ដែលស្រាវជ្រាវពីប្រវត្តិសាស្ត្រកម្ពុជាដែលសមិទ្ធិផលជាច្រើនរបស់លោក មានដូចជា «សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ៖ នយោបាយ, សង្គ្រាម, និងបដិវត្តន៍ចាប់ពីឆ្នាំ១៩៤៥», «បងធំទីមួយ ៖ ប្រវត្តិនយោបាយរបស់ ប៉ុល ពត» និង«សម្ដេងពីមន្ទីរស-២១» ។ សាស្ត្រាចារ្យ ដេវីត ឆេនល័រ គឺជាទីប្រឹក្សាជាន់ខ្ពស់មួយរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើផ្នែករៀបរៀងសៀវភៅ ។

**បណ្ឌិត ចន ឆរឆឹអារី** ជាសាស្ត្រាចារ្យផ្នែកច្បាប់របស់សកលវិទ្យាល័យច្បាប់មីឈីហ្គេន ។ ការស្រាវជ្រាវរបស់លោកផ្តោតទៅលើច្បាប់អន្តរជាតិ និងសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ មុននឹងក្លាយជាមេធាវីផ្នែកសិទ្ធិមនុស្ស លោកបានបង្រៀនប្រវត្តិសាស្ត្រនៅសាលាអាល់បៀន (Albion College) អស់រយៈពេល១០ឆ្នាំ ។ លោកទទួលបានសញ្ញាប័ត្រកិត្តិយសផ្នែក JD លើការសិក្សាពីសហរដ្ឋអាមេរិកពីសកលវិទ្យាល័យច្បាប់សូស៊ីក បណ្ឌិតផ្នែកប្រវត្តិសាស្ត្រទំនើប (American Studies from Sussex University) ពីសកលវិទ្យាល័យអក់ហ្វត(Oxford University) និងJDពីសកលវិទ្យាល័យស្តេនហ្វតដែលនៅទីនោះលោកបានក្លាយជានិស្សិតដំបូងគេបង្អស់ដែលទទួលបានពានរង្វាន់ ខាលម៉ាសាន់ ហ្វ្រេងឃ្លីន (Carl Mason Franklin Prize) ផ្នែកច្បាប់អន្តរជាតិចំនួនពីរលើក ។

**ឆាំង យុ** ជានាយកវិទ្យាស្ថានស្លឹករឹត និងនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតពីរបប «វាលពិឃាត» នៃសម័យខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងដោយកម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សកលវិទ្យាល័យយែល ហើយបានក្លាយជាអង្គការក្រៅរដ្ឋាភិបាលរបស់កម្ពុជាឯករាជ្យនៅឆ្នាំ១៩៩៧ ក្រោមការដឹកនាំរបស់លោក ឆាំង យុ ។

លោក ឆាំង យុ បានទទួលពានរង្វាន់សេរីភាពទ្រូម៉ាន់-រីហ្គេន ពីស្ថាប័នជនរងគ្រោះនៃបូជនីយដ្ឋានកុម្មុយនីស្តនៅរដ្ឋវ៉ាស៊ីនតោនឌីស៊ីនៅឆ្នាំ២០០០ ។ លោកត្រូវបានតែងតាំងនៅក្នុងចំណោម «វីរៈបុរសចំនួន៦០នាក់នៅអាស៊ី» របស់ទស្សនាវដ្តីថាមស៍ នៅឆ្នាំ២០០៦ និងនៅក្នុងទស្សនាវដ្តី «ថាមស៍

១០០»ជាបុគ្គលដែលមានឥទ្ធិពលខ្ពស់នៅក្នុងពិភពលោកនៅឆ្នាំ២០០៧សម្រាប់គោលជំហរប្រឆាំងនឹងនិទណ្ឌភាពនៅប្រទេសកម្ពុជា និងប្រទេសផ្សេងទៀត។ នៅឆ្នាំ២០១០ លោកត្រូវបានចាត់ទុកជាអ្នកប្រាជ្ញជាន់ខ្ពស់ប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃសកលវិទ្យាល័យកាលីហ្វ័រញ៉ានៅ ប៊ឺឃ្លី និង សាកលវិទ្យាល័យការលីហ្វ័រញ៉ា។

**ឡូរ៉ា សាំមី** បានចូលរៀនថ្នាក់មហាវិទ្យាល័យនៅសកលវិទ្យាល័យហ៊ុល ប្រទេសអង់គ្លេស ក្នុងឆ្នាំ ១៩៩៤។ លោកស្រីគឺជាអតីតសាស្ត្រាចារ្យផ្នែកនយោបាយ និងទំនាក់ទំនងអន្តរជាតិនៃសកលវិទ្យាល័យលែនខាស្ទឺ(Lancaster University) (១៩៧៣-១៩៩៨) ហើយមានតួនាទីជាសាស្ត្រាចារ្យគោចរនៅសកលវិទ្យាល័យជូឡាឡុងកន (Chulalongkorn University) (ប្រទេសថៃ) និងសកលវិទ្យាល័យខណែល(Cornell University) (សហរដ្ឋអាមេរិក) ។ ក្នុងនាមជាអ្នក ជំនាញផ្នែកការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរនយោបាយក្នុងប្រទេសកម្ពុជា និងទិដ្ឋភាពលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រព័ន្ធនយោបាយនៅទ្វីបអាស៊ី លោកស្រីគឺជាវាគ្មិនរបស់សិក្ខាសាលាអន្តរជាតិជាប្រចាំ។ បច្ចុប្បន្ននេះ លោកស្រីកំពុងចូលរួមស្រាវជ្រាវ ស្តីពីការធ្វើអន្តោប្រវេសន៍ដោយបង្ខំវិសមភាព និងអភិបាលកិច្ចលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។

**ឌី ខាំបូលី** បានផ្តើមបំពេញការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ២០០៣មក។ បូលី បានសរសេរអត្ថបទជាច្រើន ដែលត្រូវបានចុះផ្សាយនៅក្នុងទំព័រទស្សនាវដ្តី«ស្វែងរកការពិត» និងជាអ្នកសម្របសម្រួលគម្រោងស្តីពីការសិក្សាកម្ពុជាប្រជាធិបតេយ្យ។ បូលីបាន ទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រផ្នែកភាសាអង់គ្លេសពីសកលវិទ្យាល័យភូមិន្ទភ្នំពេញនិងបរិញ្ញាប័ត្រពាណិជ្ជកម្មពីវិទ្យាស្ថានជាតិគ្រប់គ្រង។ បូលី ធ្លាប់បានទៅសិក្សាមុខវិជ្ជាពីអំពើប្រល័យពូជសាសន៍នៅសកលវិទ្យាល័យ កុងខដៀរ (Concordia University) ប្រទេសកាណាដា និងធ្លាប់បានទៅធ្វើកម្មសិក្សានៅសារមន្ទីរប្រល័យពូជសាសន៍ និងវិទ្យុសម្លេងសហរដ្ឋអាមេរិកនៅរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ីសហរដ្ឋអាមេរិក។ បូលី បានបញ្ចប់ការសិក្សា អនុបណ្ឌិតផ្នែកកិច្ចការអន្តរជាតិ នៅសកលវិទ្យាល័យរ៉ាត់ហ្គ័រ សហរដ្ឋអាមេរិក។

**អាឡិកហេរុនឌឺ ហ៊ីនតុន** គឺជាសាស្ត្រាចារ្យជំនួយផ្នែកនរវិទ្យារបស់សកលវិទ្យាល័យរ៉ាត់ហ្គ័រ (Rutgers University) ។ លោក បណ្ឌិត ហ៊ីនតុន ត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់ការស្រាវជ្រាវរបស់លោកស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ សៀវភៅរបស់លោកដែលត្រូវបានបោះពុម្ពថ្មីៗនេះ មានដូចជា *ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស? កម្ពុជានៅក្នុងស្រមោលនៃអំពើប្រល័យពូជសាសន៍*។ ជាមួយគ្នានោះ លោកក៏ធ្វើជាទីប្រឹក្សាឲ្យបុគ្គលិកបួននាក់របស់មជ្ឈមណ្ឌល ដែលកំពុងតែសិក្សាសម្រាប់ថ្នាក់ឧត្តមសិក្សាជាន់ខ្ពស់នៅសាកលវិទ្យាល័យរ៉ាត់ហ្គ័រ ហើយក៏ជាទីប្រឹក្សាម្នាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។

**អេង កុកថាយ** ជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានធ្វើការអស់រយៈពេល៩ឆ្នាំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានធ្វើជាអ្នកគ្រប់គ្រងគម្រោងជាច្រើនរួមមានគម្រោងផ្នែកស្រាវជ្រាវ ផ្នែកចងក្រងឯកសារទស្សនាវដ្តី សៀវភៅស្វែងរកគ្រួសារ សៀវភៅនៃការចងចាំ និងការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល ការធ្វើដំណើរចុះតាមខេត្តធ្វើបទសម្ភាស និងការវាយតម្លៃលើគម្រោងជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បច្ចុប្បន្ននេះលោកកំពុងតែសរសេរនិក្ខេបបទសម្រាប់ថ្នាក់បណ្ឌិតផ្នែកកិច្ចការអន្តរជាតិនៅសកលវិទ្យាល័យរ៉ាត់ហ្គ័រ ។ ការស្រាវជ្រាវរបស់លោក គឺផ្តោតលើបទពិសោធរបស់ជនជាតិចាម-ម៉ូស្លីមក្រោមរបបខ្មែរក្រហម និងការកសាងអត្តសញ្ញាណឡើងវិញរបស់ជនជាតិចាមក្រោយពីអំពើប្រល័យពូជសាសន៍ ។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកសន្តិភាព និងការសិក្សាពីជម្លោះនៅសកលវិទ្យាល័យខូវិនទ្រី (Coventry University) ចក្រភពអង់គ្លេសនៅឆ្នាំ២០០៨និងសញ្ញាបត្រអនុបណ្ឌិតផ្នែកកិច្ចការអន្តរជាតិពីសាកលវិទ្យាល័យរ៉ាត់ហ្គ័រក្នុងឆ្នាំ២០០៧ ។ លោក អេង កុកថាយ ក៏ជានិស្សិតម្នាក់ដែលទទួលបានអាហារូបករណ៍ហ្វុលប្រាយ (Fulbright Scholar) របស់សហរដ្ឋអាមេរិក ។ លោកបានចូលរួមសរសេរអត្ថបទទាំងភាសាខ្មែរ និងអង់គ្លេសដល់ទស្សនាវដ្តីក្នុងស្រុក ។ ជាមួយគ្នានេះ លោកក៏បានចូលរួមជាញឹកញាប់នៅក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុ ដែលពិភាក្សាពីអំពើប្រល័យពូជសាសន៍ យុត្តិធម៌ និងសិទ្ធិមនុស្ស ។

**ចាយ៉ា រ៉ាមជី ណូហ្គាលីស** ជាសាស្ត្រចារ្យជំនួយផ្នែកច្បាប់នៅសាលាច្បាប់បៀស្លេយ នៃសាកលវិទ្យាល័យថេមផល(Temple University) ។ លោកស្រីទទួលបានJDពីសាលាច្បាប់នៃសាកលវិទ្យាល័យយ៉េល និងអនុបណ្ឌិតច្បាប់កិត្តិយសពីមជ្ឈមណ្ឌលច្បាប់នៃសាកលវិទ្យាល័យចចថោន (George Town University) និងបរិញ្ញាបត្រកិត្តិយសពីសាកលវិទ្យាល័យកាលីហ្វ័រញ៉ាប៊ឺក្លេយ ។ លោកស្រីបានធ្វើជាទីប្រឹក្សាផ្នែកច្បាប់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់តាំងពីឆ្នាំ២០០៧ម្ល៉េះ ។

លោកស្រីសាស្ត្រាចារ្យសរសេរអត្ថបទស្រាវជ្រាវជាច្រើនទាក់ទងនឹងសិទ្ធិមនុស្សអន្តរជាតិ និងយុត្តិធម៌អន្តរកាល ដោយផ្តោតជាពិសេសទៅលើការរៀបចំស្ថាប័ន និងដំណើរការ ។ សៀវភៅបោះពុម្ពផ្សាយថ្មីៗរបស់លោកស្រីរួមមាន ការរៀបចំយុត្តិធម៌អន្តរកាលតាមរបៀបប្រពៃណី : វិធីសាស្ត្រដំណើរការពហុនិយម បោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិ មីឆីហ្គេន ស្តីពីច្បាប់អន្តរជាតិ និង ការចោទសួរពីកម្រិតនៃការរងគ្រោះថ្នាក់ៈ ស្ត្រី,ទេសន្តរប្រវេស៍, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បោះពុម្ពផ្សាយក្នុងការ ត្រួតពិនិត្យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

**លី សុខឃាង** គឺជាសហប្រធានគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជួយអ្នករស់រានមានជីវិត និងប្រជាពលរដ្ឋកម្ពុជាផ្សេងទៀតឲ្យបានតាមដានដំណើរការនីតិវិធីរបស់តុលាការ និងសិក្សាពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកសន្តិភាពនិងការផ្សះផ្សាពីសាកលវិទ្យាល័យខូវិនទ្រី(Coventry University) នៅចក្រភពអង់គ្លេស ហើយបច្ចុប្បន្ននេះគឺជាបេក្ខជនបណ្ឌិតនៅឯសាកលវិទ្យាល័យនេះដែរ ។ លោកក៏ធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលពីវិទ្យាស្ថានសម្រាប់ការស៊ើបអង្កេតលើបទឧក្រិដ្ឋកម្មអន្តរជាតិ នៅប្រទេសអៀរឡង់(Ireland) ។

**ណេឡា ណាវ៉ារ៉ូ** គឺជាគ្រូបង្រៀនផ្នែកភាសាទំនើបនិងបុរាណ និងអក្សរសាស្ត្រ ។ លោកស្រី គឺជាសមាជិកម្នាក់ ផ្នែកភាសាអង់គ្លេស និងជាគ្រូប្រឹក្សាការបង្រៀននិស្សិត នៅសកលវិទ្យាល័យរ៉ាត់ហ្គ័រ (Rutgers University) ។ លោកស្រីបាន បង្រៀននៅសាកលវិទ្យាល័យកូឡុមបៀ (Columbia

University) និងសាកលវិទ្យាល័យអប់រំអន្តរជាតិសៀងហៃ(Shanghai International Studies University) ប្រទេសចិន ជាទីប្រឹក្សាផ្នែកអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកប្រឹក្សាផ្នែកវិជ្ជាជីវៈ និងកម្មវិធីសិក្សាលើផ្នែកអនុវត្តភាសាវិទ្យា។ លោកស្រីបានបណ្តុះបណ្តាលគ្រូបង្រៀន និងរៀបចំកម្មវិធីសិក្សា សម្រាប់អ្នកបោះពុម្ពផ្សាយនិងអង្គការក្រៅរដ្ឋាភិបាលនៅទូទាំងពិភពលោក។ បន្ថែមលើការបង្រៀន និងស្រាវជ្រាវ លោកស្រីគឺជាទីប្រឹក្សាយោបល់សម្រាប់អ្នកបោះពុម្ពផ្សាយកម្មវិធីក្រសួងអប់រំនិង វិទ្យាស្ថានអប់រំ នៅសហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀតអំពីបញ្ហា ទាក់ទងនឹងការអភិវឌ្ឍកម្មវិធីសិក្សា ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ការបង្រៀននិងបច្ចេកវិទ្យា វគ្គបណ្តុះបណ្តាលចម្រុះវប្បធម៌ និងការអប់រំអន្តរជាតិ។

**គង់ ភូមិកា** ជាអនុប្រធាននាយកដ្ឋានឧត្តមសិក្សា។ លោក ធ្លាប់មានបទពិសោធបង្រៀនអស់រយៈពេល១៩ឆ្នាំ នៅសាកលវិទ្យាល័យព្រះសីហនុរាជា វិទ្យាស្ថានជាតិអប់រំ សាកលវិទ្យាល័យភូមិន្ទច្បាប់និងសេដ្ឋកិច្ច និងសាកលវិទ្យាល័យដទៃទៀត។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតខាងការអប់រំនៅឆ្នាំ២០០៤ សញ្ញាបត្រអធិការកិច្ចអប់រំនៅឆ្នាំ២០០២ និងបរិញ្ញាបត្រខាងសិល្បៈនៃសាកលវិទ្យាល័យភ្នំពេញ។

***លោក វិន ចាន់ណារេត*** ជានាយកប្រតិបត្តិនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ប្រចាំសាខាស្ទឹងមានជ័យ។ លោក វិន ចាន់ណារេត ធ្លាប់បម្រើការជាសាស្ត្រាចារ្យមហាវិទ្យាល័យ តាំងពីឆ្នាំ២០០៨មកម្ល៉េះ។ លោក បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតចំនួនពីរ រួមមាន អនុបណ្ឌិតច្បាប់ និងអនុបណ្ឌិតខាងការអប់រំ។ លោក ក៏ធ្លាប់ធ្វើការជាបុគ្គលិកនៃក្រុមប្រឹក្សាអភិវឌ្ឍកម្មវិធីសិក្សា។

***លោក វង់ សុធារ៉ា*** ជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រ និងសិលាចារិកសាស្ត្រកម្ពុជា និងអនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្រៅពីបទពិសោធន៍បង្រៀនជាប្រចាំអស់រយៈពេល១៨ឆ្នាំ ស្តីពីប្រវត្តិសាស្ត្រនិងសិលាចារិកសាស្ត្រកម្ពុជា និងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍

លោក ធ្លាប់មានបទពិសោធធ្វើការជាមួយអង្គការយូណេស្កូ (UNESCO) និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំង ការសរសេរសេរសម្រាប់ការស្រាវជ្រាវ ។ ឥឡូវនេះ លោកជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបក្នុងចន្លោះឆ្នាំ១៩៥៣រហូតដល់បច្ចុប្បន្ន ដែលរាប់បញ្ចូលទាំងសម័យខ្មែរក្រហមផង ។

***លោក ហា ស៊ីន*** ជាសាស្ត្រាចារ្យនៅអង្គការស៊ីវ៉ូ (CYVO) និងសាកលវិទ្យាល័យបៀលប្រាយ (Build Bright University) ចាប់តាំងពីឆ្នាំ២០០០ ។ លោក ជានាយកដេប៉ាតឺម៉ង់ឆ្នាំសិក្សាមូលដ្ឋានរបស់សាកលវិទ្យាល័យ ។ លោកស្ថិតនៅក្នុងក្រុមការងារ ដើម្បីរៀបចំប្រជុំនៃសមាគមសភាអាស៊ានដើម្បីសន្តិភាព (AAPP) នៅឆ្នាំ២០០១ ដែលនៅពេលនោះ ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះសម្រាប់រដ្ឋចំនួន៤៣ ។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតខាងការគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យបៀលប្រាយ និងបរិញ្ញាបត្រអក្សរសាស្ត្រភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោកក៏បានទទួលសញ្ញាបត្រគរុកោសល្យពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគភ្នំពេញ ។

***លោក សំបូរ ម៉ាំណារ៉ា*** ជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅឯសាកលវិទ្យាល័យបញ្ញាសាស្ត្រ និងជាអនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោកបានបង្រៀននៅតាមសាកលវិទ្យាល័យផ្សេងៗទៀតជាច្រើន ។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតខាងប្រវត្តិសាស្ត្រពីសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រនីញ៉ា និងជាអ្នកជំនាញខាងប្រទេសកម្ពុជានៅក្នុងក្រុមត្រួតពិនិត្យសេចក្តីព្រាងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មុនពេលបោះពុម្ពផ្សាយ ។

***ឡាយ សុបញ្ញា*** ជាអនុប្រធាននាយកដ្ឋានរៀបចំផែនការ បណ្តុះបណ្តាល និងស្រាវជ្រាវ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។ លោកបានចាប់ផ្តើមបម្រើក្នុងវិស័យសាធារណៈនៅក្នុងខែមិថុនា ឆ្នាំ២០០៣ ជាមួយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជានៃការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី ។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតខាងអប់រំពីសាកលវិទ្យាល័យគ្រឹះស្ថានសាកលវិទ្យាល័យអាន់ជេឡេស(Angeles University Foundation) នៅប្រទេសហ្វីលីពីនកាលពីឆ្នាំ ២០០៦ ។

**បញ្ជីសាកលវិទ្យាល័យ**

**ក្រោមក្រសួងអប់រំ យុវជន និងកីឡា**

១. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

២. សាកលវិទ្យាល័យភូមិន្ទ នីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច

៣. សាកលវិទ្យាល័យជាតិគ្រប់គ្រង

៤. សាកលវិទ្យាល័យជាស៊ីមកំចាយមារ

៥. សាកលវិទ្យាល័យ ស្វាយរៀង

៦. សាកលវិទ្យាល័យ មានជ័យ

៧. សាកលវិទ្យាល័យ បាត់ដំបង

៨. វិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា

៩. សាកលវិទ្យាល័យ ន័រតុន

១០. សាកលវិទ្យាល័យ បៀលប្រាយ

១១. សាកលវិទ្យាល័យ បញ្ញាសាស្រ្តកម្ពុជា

១២. សាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ

១៣. សាកលវិទ្យាល័យ ចំរើនពហុបច្ចេកវិទ្យា

១៤. សាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា

១៥. សាកលវិទ្យាល័យ អន្តរជាតិ

១៦. សាកលវិទ្យាល័យ មេគង្គកម្ពុជា

១៧. សាកលវិទ្យាល័យ កម្ពុជា

១៨. សាកលវិទ្យាល័យ វេស្ទើន

១៩. សាកលវិទ្យាល័យ អាយអាយស៊ីនៃបច្ចេកវិទ្យា

២០. សាកលវិទ្យាល័យ ខេមរៈ

២១. សាកលវិទ្យាល័យ អង្គរខេមរា

២២. សាកលវិទ្យាល័យ អង្គរ

២៣. សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

២៤. សាកលវិទ្យាល័យ ធនធានមនុស្ស

២៥. សាកលវិទ្យាល័យ ស៊ីធី

២៦.	សាកលវិទ្យាល័យ គ្រប់គ្រងនិងសេដ្ឋកិច្ច

២៧.	សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ

២៨.	សាកលវិទ្យាល័យ ឡាយហ្វ

២៩.	សាកលវិទ្យាល័យ សោស័អ៊ីសថ៍អេយសៀ

៣០.	សាកលវិទ្យាល័យ ចេនឡា

៣១.	សាកលវិទ្យាល័យ លីមកុកវីង

៣២.	សាកលវិទ្យាល័យ ខេ្មរបច្ចេកវិទ្យា និងគ្រប់គ្រង

៣៣.	សាកលវិទ្យាល័យ បញ្ញាជាតិ

៣៤.	សាកលវិទ្យាល័យ ហ្សាម៉ាន់អន្តរជាតិ

៣៥.	សាកលវិទ្យាល័យ កម្ពុជាអន្តរជាតិ

៣៦.	សាកលវិទ្យាល័យអន្តរជាតិឌូវី

៣៧.	វិទ្យាស្ថាន ភ៉ាន់ដា

៣៨.	វិទ្យាស្ថាន ស៊ីតិក

៣៩.	វិទ្យាស្ថាន ប៊ែលធីអន្តរជាតិ

៤០.	វិទ្យាស្ថាន ក្រុងអង្គរ

៤១.	វិទ្យាស្ថាន អភិវឌ្ឍន៍អាស៊ីសច្ចៈ

៤២.	វិទ្យាស្ថាន សង្គមសាស្ត្រនិងបច្ចេកវិទ្យា

៤៣.	វិទ្យាស្ថាន គ្រប់គ្រងនិងអភិវឌ្ឍន៍

៤៤.	វិទ្យាស្ថាន អប់រំកម្ពុជា

៤៥.	វិទ្យាស្ថាន ប្រាយហ្វូប

៤៦.	វិទ្យាស្ថាន អប់រំពាណិជ្ជសាស្ត្រ

៤៧.	វិទ្យាស្ថាន អាយស៊ីអេស

៤៨.	វិទ្យាស្ថាន ខេមរាសាស្ត្រ

៤៩.	វិទ្យាស្ថាន អ៊ិនធ័ររេដ

៥០.	វិទ្យាស្ថាន អន្តរទ្វីបអាមេរិកកាំង

៥១.	វិទ្យាស្ថាន បេតអែល

៥២.	វិទ្យាស្ថាន សន្តប៉ូល

៥៣. វិទ្យាស្ថាន វ៉ាហុល អ៊ិនធើណេសិនណល ខលលីច

៥៤. វិទ្យាស្ថាន ហិរញ្ញវត្ថុកម្ពុជា

៥៥. វិទ្យាស្ថាន ខេមរអេង

៥៦. វិទ្យាស្ថានគ្រប់គ្រង ភី ស៊ី អិល

៥៧. វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៥៨. វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ

៥៩. វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ

៦០. មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា

៦១. វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

៦២. វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា

៦៣. វិទ្យាស្ថានពហុបច្ចេកទេស បាត់ដំបង

៦៤. វិទ្យាស្ថានបច្ចេកវិទ្យា បាត់ដំបង

៦៥. វិទ្យាស្ថានពហុបច្ចេកទេស កំពត

៦៦. វិទ្យាស្ថានបច្ចេកវិទ្យាខស្សរាហកម្ម

៦៧. វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច

៦៨. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា

៦៩. វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា

៧០. វិទ្យាស្ថានពាណិជ្ជសាស្ត្រនាគព័ន្ធ

៧១. វិទ្យាស្ថានខ្មែរជំនាន់ថ្មី

៧២. វិទ្យាស្ថានអនាគតយុវជនកម្ពុជា

៧៣. វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិ

៧៤. វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត

៧៥. វិទ្យាស្ថានប៉ែលតុន អន្តរជាតិ

៧៦. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ

## ក្រោមក្រសួងការពារជាតិ

៧៧. សាកលវិទ្យាល័យការពារជាតិ

៧៨. សាលានាយទាហ៊ានសកម្មគ្នាតពង

៧៩. វិទ្យាស្ថានវិទ្យាសាស្រ្តសុខាភិបាលខេមរៈភូមិន្ទ

៨០. វិទ្យាស្ថានទព័ជើងគោក (កំពង់ស្ពឺ)

៨១. វិទ្យាស្ថានបច្ចេកយោធា តេជោ ហ៊ុន សែន (កំពង់ស្ពឺ)

## ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៨២. សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៨៣. សាលាជាតិកសិកម្មកំពង់ចាម

៨៤. សាលាជាតិកសិកម្មព្រែកលាប

## ក្រោមក្រសួងសុខាភិបាល

៨៥. សាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល

៨៦. សាលាបណ្តុះបណ្តាលថែទាំវេជ្ជសាស្រ្ត

## ក្រោមក្រសួងធម្មការ និងសាសនា

៨៧. ពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជ

៨៨. ពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជា

## ក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បះ

៨៩. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

## ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៩០. វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ក្រោមក្រសួងមហាផ្ទៃ

៩១.　　បណ្ឌិត្យសភានគរបាលកម្ពុជា

**ក្រោមក្រសួងសាធារណការ និងដឹកជញ្ជូន**

៩២.　　វិទ្យាស្ថាននាវាចរណ៍កម្ពុជា

**ក្រោមទីស្តីការគណៈរដ្ឋមន្ត្រី**

៩៣.　　រាជបណ្ឌិតសភាកម្ពុជា

**ធនាគារជាតិនៃកម្ពុជា**

៩៤.　　មជ្ឈមណ្ឌលបច្ចេកទេសធនាគារ

**កំណត់សម្គាល់ ៖**

*យោងតាមលោក គង់ ភូមិកា អនុប្រធាននាយកដ្ឋានឧត្តមសិក្សា សាកលវិទ្យាល័យ(១-៥៧)ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ដូច្នេះ ក្រសួងអាចអញ្ជើញសាស្ត្រាចារ្យមកចូលរួមវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ។ ក្នុងចំណោមសាកលវិទ្យាល័យ និងវិទ្យាស្ថានទាំង៥៧នេះ គ្រឹះស្ថានចំនួន១៥ មានទីតាំងនៅតាមបណ្តាខេត្ត និងចំនួន៤២នៅភ្នំពេញ ។ សាកលវិទ្យាល័យ (៥៨-៩៤) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងស្ថាប័នផ្សេងៗ ។*